# សេចក្តីថ្លែងការរួម ស្តីពី
# បញ្ហា និងការព្រួយបារម្ភ
# ពីផលប៉ះពាល់ធ្ងន់ធ្ងរទាក់ទងនឹងអភិបាលកិច្ចធនធានធម្មជាតិ

រាជធានីភ្នំពេញ ថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០១២

យើងជាតំណាងសហគមន៍មកពីខេត្ត បាត់ដំបង កំពង់ស្ពឺ តាកែវ បន្ទាយមានជ័យ ឧត្តរមានជ័យ ពោធិសាត់ រតនៈគីរី មណ្ឌលគីរី ព្រះវិហារ កោះកុង ស្ទឹងត្រែង កំពង់ធំ កំពង់ចាម កំពង់ឆ្នាំង សៀមរាប ក្រុងព្រះសីហនុ ស្វាយរៀង កំពត ក្រចេះ និងអង្គការសង្គមស៊ីវិលរួមមាន សមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា(ADHOC) វិទ្យាស្ថានតស៊ូមតិនិងគោលនយោបាយ(API) គណៈកម្មាធិការប្រព្រឹត្តិកម្មនៃអង្គការសមាគមការពារសិទ្ធិមនុស្សកម្ពុជា(CHRAC) មជ្ឈមណ្ឌលអប់រំច្បាប់សំរាប់សហគមន៍(CLEC) គណៈកម្មការរៀបចំការបោះឆ្នោត ដោយសេរីនិងយុតិធម៌នៅកម្ពុជា (COMFREL) សម្ព័ន្ធភាពកម្ពុជាដើម្បីតម្លាភាពចំណូលធនធាន (CRRT) ស្ម័គ្រចិត្តដើម្បីសង្គម(CVS) អង្គការអភិវឌ្ឍន៍និងភាពជាដៃគូក្នុងសកម្មភាព(DPA) អង្គការយេនឌ័រនិងការអភិវឌ្ឍន៍ដើម្បីកម្ពុជា(GAD/C) ក្រុមការងារពិសេសសិទ្ធិលំនៅឋាន(HRTF) អង្គការគាំទ្រសហគមន៍ជនជាតិដើមភាគតិច(ICSO) អង្គការយុវជនខ្មែរនិងការអភិវឌ្ឍន៍សង្គម (KYSD) អង្គការជីវិតថ្លៃថ្នូរ(LWD) អង្គការស្ដារកម្ពុជា(Star Kampuchea) វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្ដីពីកម្ពុជា (The NGO Forum on Cambodia) អង្គការវីជីឡែន (Vigilance) អង្គការទស្សនៈពិភពលោក (WVC) អង្គការកម្មវិធីអភិវឌ្ឍន៍ធនធានយុវជន(YRDP) និងអង្គការសង្គមស៊ីវិលផ្សេងៗ ប្រមាណ៣០០នាក់នៅកម្ពុជា សូមធ្វើសេចក្តីថ្លែងការណ៍រួមគ្នាមួយចេញពីបញ្ហាក្នុងសន្និសីទតស៊ូ មតិថ្នាក់ជាតិប្រចាំឆ្នាំលើកទី៧ស្តីពី "**ធ្វើការរួមគ្នាដើម្បីអភិបាលកិច្ចល្អលើវិស័យដីធ្លី និងធនធានធម្មជាតិនៅកម្ពុជា**" ថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១២ នៅសណ្ឋាគារអ៊ិមភើរៀល និងហ្គាឌិន រាជធានីភ្នំពេញ។

យើងជាសហគមន៍ និងអង្គការសង្គមស៊ីវិល មកពីខេត្តទាំងអស់ខាងលើនៅកម្ពុជាសូមធ្វើការកោតសរសើរចំពោះការខិតខំរបស់រាជរដ្ឋាភិបាល ដើម្បីអភិបាលកិច្ចល្អលើវិស័យដីធ្លី និងធនធានធម្មជាតិនៅប្រទេសកម្ពុជា។ សន្និសីទតស៊ូមតិថ្នាក់ជាតិប្រចាំឆ្នាំលើកទី៧ សូមលើកឡើងនូវបញ្ហាដែលជាការព្រួយបារម្ភយ៉ាងខ្លាំង និងអនុសាសន៍ពាក់ព័ន្ធនឹងផលបះពាល់ធ្ងន់ធ្ងរមួយចំនួនដូចខាងក្រោម៖

## ១.បញ្ហានៃវិស័យឧស្សាហកម្ម និស្សារណកម្ម

វិស័យឧស្សាហកម្មនិស្សារណកម្ម គឺជាវិស័យមួយដែលរដ្ឋាភិបាលកម្ពុជាដែលបាននឹងកំពុងទទួលនូវប្រាក់ចំណូលយ៉ាងសំខាន់ដើម្បីអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ ប៉ុន្តែកម្ពុជានៅមិនទាន់បានត្រៀមខ្លួនដើម្បីអភិវឌ្ឍន៍វិស័យនេះនៅឡើយ។ បច្ចុប្បន្នក្របខណ្ឌច្បាប់ និងបច្ចេកទេសនៅមាន

កម្រិត ដែលបណ្តាលឲ្យមានការលំបាកក្នុងការគ្រប់គ្រងថវិកាដ៏ច្រើនសន្ធឹកសន្ធាប់នេះ។ ផ្ទុយទៅវិញវិស័យឧស្សាហកម្មនិស្សារណកម្ម បានបណ្តាលឲ្យមានផលប៉ះពាល់ជាអវិជ្ជមានទៅលើបរិស្ថានតាមរយៈការប្រើប្រាស់សារធាតុគីមី ដែលបណ្តាលឲ្យបាត់បង់គុណភាពទឹក ដី ផលិតផលកសិកម្ម សុខភាពមនុស្ស និងសត្វ។ សហគមន៍មិនបានទទួលព័ត៌មាន និងការពិគ្រោះយោបល់យ៉ាងពេញលេញជាមុនក្នុងការធ្វើសេចក្តីសំរេចចិត្តរាល់គំរោងអភិវឌ្ឍន៍ធនធានរ៉ែ ដែលបណ្តាលឲ្យមានការរំលោភសិទ្ធិមនុស្ស ជាពិសេសជនជាតិដើមភាគតិច។

➢ **សមិទ្ធិផលរបស់រាជរដ្ឋាភិបាល**

រដ្ឋាភិបាលកំពុងធ្វើសេចក្តីព្រៀងច្បាប់មួយចំនួន ដើម្បីគ្រប់គ្រងវិស័យឧស្សាហកម្ម និស្សរណកម្ម បានកសាងហេដ្ឋារចនាសម្ព័ន្ធមួយចំនួននៅក្នុងតំបន់អាជីវកម្មរ៉ែ និងបានទូទាត់សំណងមួយចំនួនតូចដល់សហគមន៍ដែលរងផលប៉ះពាល់ពីអាជីវកម្មរ៉ែ។

➢ ***អនុសាសន៍***

***សំរាប់រដ្ឋាភិបាល***

1. ដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ត្រូវមានការចូលរួមយ៉ាងពេញលេញពីសាធារណជន ហើយមានការជូនដំណឹងជាមុនយ៉ាងតិចរយៈពេល ១ខែ
2. បង្កើតអោយមានមូលនិធិចំណូលដែលបានមកពីវិស័យប្រេង រ៉ែ និងឧស្ម័នសម្រាប់កូនចៅជំនាន់ក្រោយ ដោយមានការគ្រប់គ្រងពីគណកម្មការឯករាជ្យមួយ ហើយមានការផ្សព្វផ្សាយជាសាធារណៈអំពីការប្រើប្រាស់មូលនិធិឲ្យបានទៀងទាត់។
3. កសាងសមត្ថភាពបច្ចេកទេសដល់ប្រជាពលរដ្ឋកម្ពុជាទៅលើវិស័យឧស្សាហកម្ម និស្សរណកម្ម។
4. ពង្រឹងការអនុវត្តច្បាប់ពាក់ព័ន្ធ លើវិស័យឧស្សាហកម្ម និស្សរណកម្មអោយកាន់តែប្រសើរ
5. អនុម័តច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន និងបើកចំហរព័ត៌មានទាំងឡាយ ដែលពាក់ពន្ធ័ទៅនឹងវិស័យឧស្សាហកម្ម និស្សរណកម្មដែលរួមមាន ចំណូល ចំណាយ កិច្ចសន្យា និងអាជ្ញា បណ្ណ័ជាសារធារណៈជាដើម ។
6. បញ្ឈៀស និងបញ្ឈប់ការផ្តល់សម្បទានរ៉ែទាំងឡាយ ដែលប៉ះពាល់ទៅលើដីសហគមន៍សម្ភូហភាពជនជាតិដើមភាគតិច ឬ ដីកំពុងស្ថិតក្នុងដំណើរការចុះបញ្ជីដីសម្ភូហភាពរបស់សហគមន៍។
7. ធ្វើវិសោធនកម្មច្បាប់ស្តីពីការគ្រប់គ្រង និងធ្វើអាជីវកម្មរ៉ែនិងលើកទឹកចិត្តអោយមានការពិគ្រោះយោបល់ជាមួយសាធារណជនលើការតាក់តែងច្បាប់សាជាថ្មីនិងច្បាប់ថ្មីៗ ដែលពាក់ព័ន្ធនឹងឧស្សាហកម្មនិស្សារណកម្ម ព្រមទាំងអនុលោមតាមបទដ្ឋានអន្តរជាតិ។

*សំរាប់វិស័យឯកជន*

1. បើកចំហរព័ត៌មានទាំងឡាយដែលទាក់ទងទៅនឹងគំរោងផែនការ កិច្ចព្រមព្រៀងជាមួយរដ្ឋាភិបាល អាជ្ញាបណ្ណ័ និងចំណូល ចំណាយដល់សាធារណជន
2. អនុវត្តលក្ខខណ្ឌដែលបានឯកភាពគ្នាជាផ្លូវការ និងផ្តល់ជាសំណងយ៉ាងពេញលេញជូនសហគមន៍ដែលរងផលប៉ះពាល់។
3. បង្កើតឲ្យមានមូលនិធិសង្គមសំរាប់គំរោងអភិវឌ្ឍសហគមន៍ និងផ្តល់នូវជំរើសមុខរបរសមស្រប។
4. ផ្តល់ឱកាសឲ្យមានការចូលរួមឲ្យពេញលេញរបស់សហគមន៍ និងសង្គមស៊ីវិលនៅក្នុងដំណើរការសិក្សារុករករ៉ែ។

*សំរាប់ដៃគូអភិវឌ្ឍន៍*

1. បន្តគាំទ្រថវិកា និងកសាងសមត្ថភាពបច្ចេកទេស ក្របខ័ណ្ឌច្បាប់ និងដំណើរការអាជីវកម្មរ៉ែដល់សហគមន៍។

## ២.បញ្ហាក្រុមជនជាតិដើមភាគតិច

ការចុះសិក្សា និងកំណត់អត្តសញ្ញាណរបស់ជនជាតិដើមតិចទូទាំងប្រទេស មិនទាន់បានអនុវត្តចប់សព្វគ្រប់នៅឡើយ។ ខ្វះការអប់រំផ្សព្វផ្សាយពីនិតិវិធីនៃការធ្វើស្វ័យអត្តសញ្ញាណ និងការចុះបញ្ជីដីសម្ហូហភាព។ ជាពិសេសសហគមន៍ជនជាតិដើមដែលនៅតំបន់ផ្សេងៗ ដែលមិនទាន់បានធ្វើស្វ័យអត្តសញ្ញាណ។ ការចូលរួម និងការយល់ដឹងពីសំណាក់អាជ្ញាធរមូលដ្ឋានចំពោះការកំណត់អត្តសញ្ញាណរបស់ជនជាតិដើមភាគតិចនៅមានកំរិត។ ដំណើរការនៃការផ្តល់អត្តសញ្ញាណជនជាតិដើមភាគតិចពីសំណាក់រាជរដ្ឋាភិបាលមានភាពយឺតយ៉ាវ។ អាទិភាពនៃការចុះបញ្ជីដីសម្ហូហភាពរបស់ជនជាតិដើមភាគតិច ត្រូវបានកំណត់ក្រោយការចុះបញ្ជីដីឯកជន។ លើសពីនេះទៀត សហគមន៍ជនជាតិដើមភាគតិចត្រូវបានបញ្ចុះបញ្ចូលក្នុងការទទួលយកកម្មសិទ្ធដីឯកជន។

- **សមទ្ធិផលរបស់រាជរដ្ឋាភិបាល**

រាជរដ្ឋាភិបាលបាននិងកំពុងវាយតំលៃនិងចុះបញ្ជីសហគមន៍ជានិតិបុគ្គលនិងដីសម្ហូលហភាព។ ផលិតនូវលិខិតគតិយុត្តិសម្រាប់ការពារបណ្តោះអាសន្ននូវដីរបស់ជនជាតិដើមភាគតិច។ បង្កើតគោលនយោបាយជាតិអភិវឌ្ឍន៍ជនជាតិដើមភាគតិច។ ការបង្កើតក្រុមការងារបច្ចេកទេសដូចជាក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងមហាផ្ទៃ ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ និងអង្គការពលកម្មអន្តរជាតិ។

- **អនុសាសន៍**

**សំរាប់រាជរដ្ឋាភិបាល**

1. ជំរុញ និងពន្លឿនការចុះបញ្ជីដីសម្ហហភាពដល់សហគមន៍ជនជាតិដើមភាគតិចឲ្យបានឆាប់រហ័ស ដើម្បីធានាបាននូវនិរន្តរភាពនៃសិទ្ធប្រើប្រាស់ដីធ្លី ធនធានធម្មជាតិ និងរក្សាបាននូវប្រពៃណីទំនៀមទំលាប់របស់ជនជាតិដើមភាគតិច ។
2. គោរពសិទ្ធិ និងទទួលស្គាល់ប្រពៃណី វប្បធម៌ ដែលធានាបាននូវការការពារសិទ្ធជនជាតិដើមភាគតិច និងរក្សាទំនៀមទំលាប់ និងប្រពៃណីរបស់គេ។
3. ត្រូវផ្សព្វផ្សាយឲ្យបានទូលំទូលាយពីនិតិវិធីនៃការចុះបញ្ជីដីសម្ហហភាព និងដីឯកជន។
4. ពិនិត្យឡើងវិញចំពោះក្រុមហ៊ុន ដែលទទួលបានសម្បទានដីសេដ្ឋកិច្ចរួចហើយ ដែលប៉ះពាល់ដីរបស់សហគមន៍ និងព្រៃឈើត្រូវផ្តល់ឲ្យសហគមន៍វិញ។
5. ត្រូវផ្តល់ព័ត៌មាន និងពិគ្រោះយោបល់ជាមុនជាមួយជនជាតិដើមភាគតិច រាល់គម្រោងអភិវឌ្ឍន៍នានា។
6. ទូទាត់សំណងសមរម្យ និងអាចទទួលយកបានដល់ជនជាតិដើមភាគតិច ដែលរងផលប៉ះពាល់ពីគម្រោងអភិវឌ្ឍន៍។
7. ត្រូវតែអនុម័តច្បាប់សិទ្ធទទួលព័ត៌មាន ដើម្បីលើកកម្ពស់ការចូលរួមនិងសិទ្ធក្នុងការធ្វើសេចក្តីសម្រេចចិត្តចំពោះការអភិវឌ្ឍសង្គមជាតិ។

## ៣.បញ្ហាព្រៃឈើ

ការផ្តល់ដីសម្បទានសេដ្ឋកិច្ចត្រួតស៊ីគ្នាជាមួយព្រៃសហគមន៍ និងសហគមន៍តំបន់ការពារ។ អាជ្ញាធរមូលដ្ឋានមួយចំនួនមិនគាំទ្រការបង្កើតសហគមន៍ព្រៃឈើ និងសហគមន៍ដែលចុះបញ្ជីមួយចំនួនខ្វះការសហការពីអាជ្ញាធរមូលដ្ឋានផងដែរ។ និតិវិធីនៃការរៀបចំសហគមន៍ព្រៃឈើមានភាពស្មុគស្មាញដោយចំណាយពេលច្រើន និងមានភាពយឺតយ៉ាវ។ មានការឈូសឆាយរំលោភព្រៃសហគមន៍ និងការកាប់ឈើរានព្រៃឈើនៅដែនសហគមន៍ព្រៃឈើពីសំណាក់អ្នកមានអំណាចឈ្មួញ និងក្រុមហ៊ុនសម្បទានសេដ្ឋកិច្ចមួយចំនួន។ មានការសាងសង់បន្ទាយទាហាននៅលើព្រៃសហគមន៍ដែលបានចុះកិច្ចព្រមព្រៀងជាមួយរដ្ឋាភិបាលរួចហើយដូចជា៖ ករណីក្នុងខេត្តឧត្តរមានជ័យ សហគមន៍ដុងបេង អណ្តូងបរ រំដួលវាសនា សហគមន៍សាមគ្គីសង្គ្រោះព្រៃឈើ។ មានការគំរាមគំហែងដល់សកម្មជនការពារព្រៃឈើ ភាគីក្រុមហ៊ុន ឈ្មួញ និងមន្ត្រីមួយចំនួន។ ខ្វះខាតការគាំទ្រហិរញ្ញវត្ថុ សម្រាប់គាំទ្រសកម្មភាពសហគមន៍ព្រៃឈើ។

### ➢ សមិទ្ធិផលរបស់រាជរដ្ឋាភិបាល

សហគមន៍ និងអង្គការមិនមែនរដ្ឋាភិបាល ដែលធ្វើការលើវិស័យព្រៃឈើ ទទួលស្គាល់បំណងរបស់រាជរដ្ឋាភិបាលកម្ពុជា ជាពិសេសការដាំដើមឈើលើដីវិចរិលដោយរដ្ឋបាលព្រៃឈើ ដូចដែលត្រូវបានលើកឡើងនៅក្នុងសូចនាករតាមដានរួម។ ប៉ុន្តែអង្គការមិនមែនរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលផ្សេងទៀត ខកចិត្តដោយសារ "ការដាំដើមឈើឡើងវិញ" រាប់បញ្ចូលទាំងការដាំដើមកៅស៊ូនៅក្នុងសម្បទានដីសេដ្ឋកិច្ច (ELCs) ក៏ដូចជាដើមអាកាស្យា និងដើមប្រេងខ្យល់។

សហគមន៍ និងអង្គការមិនមែនរដ្ឋាភិបាលសូមវាយតម្លៃខ្ពស់ចំពោះការកំណត់ព្រំប្រទល់ព្រៃឈើ និងតំបន់ការពារទៅតាមផែនការ ក៏ប៉ុន្តែយើងខ្ញុំមានការបារម្ភយ៉ាងខ្លាំងចំពោះកំណើនដ៏លឿនចំពោះចំនួនសម្បទានដីសេដ្ឋកិច្ចដែលត្រូវបានផ្តល់នៅក្នុងតំបន់ការពាររួមមានបូកគោ បុទុមសាគរ វិរៈជ័យ ឱរ៉ាល់ បឹងពែរ លំផាត់ ណាមលៀរ និងកែវសីមា។

គិតមកដល់ខែវិច្ឆិកា ឆ្នាំ២០១១ មានសហគមន៍ព្រៃឈើចំនួន១៣០ ដែលមានផ្ទៃដីសរុបទំហំ ១៩១,០៣១ហិកតា ដែលត្រូវបានអនុម័តដោយក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ។ យើងអបអរសាទរកិច្ចប្រឹងប្រែងនេះ។ ទោះជាយ៉ាងណាក្តី អង្គការមិនមែនរដ្ឋាភិបាល និងសហគមន៍មួយចំនួនបានសង្កេតឃើញថា នីតិវិធីនៃការទទួលការយល់ព្រមពីក្រសួងកសិកម្មរុក្ខា ប្រមាញ់ និងនេសាទគឺយឺត និងលំបាក ជាពិសេសនៅពេលដែលប្រៀបធៀបទៅនឹងនីតិវិធីនៃការផ្តល់សម្បទានដីសេដ្ឋកិច្ច សូម្បីតែសមាជិកនៃក្រុមការងារបច្ចេកទេសបរិស្ថាន និងព្រៃឈើ ក៏ទទួលស្គាល់ចំណុចនេះដែរ[1]។

អង្គការមិនមែនរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលទទួលស្គាល់ថា គំនិតផ្តួចផ្តើមនៃការរៀបចំផែនទីបង្ហាញផ្លូវកម្មវិធីកាត់បន្ថយការបញ្ចេញឧស្ម័នពីការបាត់បង់ និងការរិចរិលព្រៃឈើថ្នាក់ជាតិមានលក្ខណៈកាន់តែចូលរួមជាងកិច្ចដំណើរ ការរៀបចំគោលនយោបាយព្រៃឈើផ្សេងៗទៀត ដោយផ្តល់ឱកាសឲ្យអង្គការមិនមែនរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលផ្សេងទៀតលើកឡើងការបារម្ភ និងចូលរួមគំនិត។ យើងក៏ទទួលស្គាល់ផងដែរថា នៅក្នុងរចនាសម្ព័ន្ធនៃផែនទីបង្ហាញផ្លូវ នេះអនុញ្ញាតិឲ្យអង្គការមិនមែនរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលមានតំណាងនៅក្នុងក្រុមដែលធ្វើសេចក្តីសម្រេចចិត្តសំខាន់ៗ។

- **អនុសាសន៍**

1. កែសម្រួលនីតិវិធីការបង្កើតសហគមន៍ព្រៃឈើ និងពន្លឿនការផ្តល់ដីឲ្យធ្វើសហគមន៍ព្រៃឈើ
2. ត្រូវតែដោះស្រាយផលប៉ះពាល់ឲ្យមានភាពយុត្តិធម៌ និងឲ្យបានលឿន
3. ការអភិវឌ្ឍត្រូវមានការពិគ្រោះយោបល់ជាសាធារណៈជាមួយប្រជាពលរដ្ឋ ដូចបានចែងក្នុងបទដ្ឋានគតិយុត្តិ
4. គណៈកម្មាធិការគ្រប់គ្រងសហគមន៍ព្រៃឈើ និងប្រជាពលរដ្ឋ រួមទាំងអាជ្ញាធរមូលដ្ឋានត្រូវចូលរួមសហការជាមួយសហគមន៍ព្រៃឈើឲ្យបានប្រសើរ
5. ផ្សព្វផ្សាយអំពីច្បាប់ព្រៃឈើ និងបរិស្ថានឲ្យបានទូលំទូលាយ។

## ៤.បញ្ហាអនិវឌ្ឍទីក្រុង ការតាំងទីលំនៅដ្ឋានថ្មីនិងការបណ្តេញចេញដោយបង្ខំ

នៅក្នុងបរិបទដែលព្រះរាជាណាចក្រកម្ពុជាកំពុងអភិវឌ្ឍន៍ មានផលប៉ះពាល់មួយចំនួនដែលកើតចេញពីការអភិវឌ្ឍនេះទៅលើការរស់នៅរបស់ប្រជាពលរដ្ឋ ជាពិសេសបណ្តាលមកពីការបណ្តេ

ញចេញ និងការតាំងទីលំនៅថ្មី។ បញ្ហាទាំងនោះមាន ជាអាទិ៍៖ ការបណ្តេញចេញ ដោយបង្ខំដោយគ្មានសំណងសមរម្យនិងយុត្តិធម៌ ខ្វះការពិគ្រោះយោបល់ជាសាធារណៈឲ្យបានត្រឹមត្រូវមុនការអនុវត្តគំរោងអភិវឌ្ឍន៍ដែលនាំទៅដល់ការបាត់បង់ដីធ្លីលំនៅដ្ឋាន។ ការបណ្តេញអាចនាំទៅដល់ការបាត់បង់មុខរបរប្រចាំថ្ងៃ ប៉ះពាល់ដល់អនាគតរបស់កូនចៅ និងជំពាក់បំណុលគេ បាត់បង់ទ្រព្យសម្បត្តិរបស់ប្រជាពលរដ្ឋ ប៉ះពាល់ផ្លូវចិត្តរបស់កុមារនិងស្ត្រី ហើយទីបំផុតនឹងធ្វើឲ្យប្រជាពលរដ្ឋក្រីក្រ។ ជាងនេះទៀត ដោយសារការរើមកតាំងទីលំនៅនៅទីតាំងថ្មី ប្រជាពលរដ្ឋជួបផលពិបាកក្នុងការទទួលសេវាសាធារណៈដូចជា៖ ផ្សារ សាលារៀន និងមន្ទីរពេទ្យ។ល។ កង្វះការផ្សព្វផ្សាយព័តមាន និងការពិគ្រោះយោបល់ទូលំទូលាយជាមួយប្រជាពលរដ្ឋ អំពីគម្រោងផែនការអភិវឌ្ឍន៍ភាគច្រើនរបស់រាជរដ្ឋាភិបាល នាំឲ្យប្រជាពលរដ្ឋក្លាយជាជនរងគ្រោះដោយសារការរំលោភសិទ្ធិមនុស្ស និងមិនទទួលបានការដោះស្រាយសមរម្យពីគម្រោងការអភិវឌ្ឍទាំងនោះ[2]។ ម្យ៉ាងយើងក៏សង្កេតឃើញថា រាល់សកម្មភាពបណ្តេញចេញដោយអាជ្ញាធរមានសមត្ថកិច្ចតែងតែមានអំពើហឹង្សា និងការគំរាមកំហែង រហូតដល់អ្នកខ្លះដែលហ៊ានតវ៉ាត្រូវបានអាជ្ញាធរចាប់ខ្លួនបញ្ជូនទៅតុលាការ និងដាក់ឃុំឃាំង និងកាត់ទោសដោយអយុត្តិធម៌។ ចំណែកឯការដោះស្រាយសំណងទៀតសោត មិនបានធ្វើឲ្យមានការពេញចិត្តពីសំណាក់ប្រជាពលរដ្ឋភាគច្រើនទេ ប៉ុន្តែ គេត្រូវតែបង្ខំចិត្តចាកចេញពីលំនៅដ្ឋានចាស់ទៅកាន់ទីតាំងថ្មីតាមការតម្រូវរបស់អាជ្ញាធរ ឬក្រុមហ៊ុនវិនិយោគដោយមិនមានសំណងសមរម្យ ហើយអ្នកខ្លះរងនូវការរើសអើងពីអាជ្ញាធរក្នុងពេលដោះស្រាយសំណង និងជួលកាលខ្លះទៀត ក៏មានបាតុភាពអសកម្មខ្លះទៀត ដែលបង្កឡើងដោយមន្ត្រីអាជ្ញាធរមានសមត្ថកិច្ចមួយចំនួន ដូចជា ការប្រព្រឹត្តអំពើពុករលួយ និងការបាត់បង់ការទទួលខុសត្រូវក្នុងការអនុវត្តកាតព្វកិច្ចការពារប្រជាពលរដ្ឋ។ ជាលទ្ធផល បញ្ហានេះនាំទៅដល់ការបាត់បង់ជំនឿទុកចិត្តពីសំណាក់ប្រជាពលរដ្ឋរងគ្រោះចំពោះអាជ្ញាធរមានសមត្ថកិច្ចរបស់រដ្ឋ។

## ➢ សមិទ្ធិផលរបស់រាជរដ្ឋាភិបាល

ទន្ទឹងនឹងបញ្ហាប្រឈមទាំងនេះ យើងក៏បានកត់សំគាល់នូវផលវិជ្ជមានខ្លះៗពីគម្រោងការ និងគោលនយោបាយអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាល ក្នុងការធ្វើឲ្យមានសោភណ្ឌភាពទីក្រុង និងទីប្រជុំជនមួយចំនួនដូចជា៖ មានហេដ្ឋារចនាសម្ព័ន្ធសម្រាប់បង្កលក្ខណៈងាយស្រួលក្នុងការរស់នៅរបស់ប្រជាពលរដ្ឋ, មានសាលារៀនសម្រាប់ការសិក្សារបស់កូនចៅប្រជាពលរដ្ឋ និងមន្ទីរពេទ្យ សេវាសុខភាព (មជ្ឈមណ្ឌលសុខភាព មន្ទីរពេទ្យរដ្ឋ និងឯកជន) សម្រាប់បំពេញសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ, មានរោងចក្រសហគ្រាស សម្រាប់ផ្តល់ការងារដល់ប្រជាពលរដ្ឋ និងមានសំណង់អគារ (បុរី ផ្ទះល្វែង វីឡា ផ្សារទំនើប អាគារខ្ពស់ និងមជ្ឈមណ្ឌលទំនើបៗ។

## ➢ អនុសាសន៍

### សំរាប់រាជរដ្ឋាភិបាល

[2] សហគមន៍ដីក្រហម រីករាយ បឹងកក់ បុរីកីឡា និងសហគមន៍ដទៃទៀត។ ចំណែកឯ សហគមន៍ព្រលានយន្តហោះ និងសហគមន៍ដទៃទៀត ក៏បាននឹងកំពុងប្រឈមនឹងការបណ្តេញចេញ នាពេលនេះដែរ។

1. ចុះបញ្ជីដីធ្លីជាប្រព័ន្ធសម្រាប់សហគមន៍ក្រីក្រនៅតាមបណ្តាខេត្ត ក្រុង រាជធានី និងពន្លឿនការផ្តល់កម្មសិទ្ធិដីធ្លីដល់ប្រជាពលរដ្ឋនៅទាំងអស់ទូទាំងប្រទេស។
2. ត្រូវផ្សព្វផ្សាយ និងពិគ្រោះយោបល់ឲ្យបានទូលំទូលាយអំពីគំរោងអភិវឌ្ឍនានាជាមួយប្រជាពលរដ្ឋជាពិសេសសហគមន៍ដែលរស់នៅក្នុងតំបន់រងផលប៉ះពាល់ មុននឹងផ្តល់ការ អនុញ្ញាតិឲ្យក្រុមហ៊ុនវិនិយោគ។
3. រាល់ការអភិវឌ្ឍត្រូវអោយមានផលប្រយោជន៍ដល់ពលរដ្ឋនៅនឹងកន្លែងដែលត្រូវអភិវឌ្ឍន៍។
4. ធានាប្រព័ន្ធតុលាការឯករាជ្យ និងយុត្តិធម៌ ហើយគោរពសិទ្ធិមនុស្ស និងបញ្ឈប់ប្រើប្រាស់ប្រព័ន្ធតុលាការមកគាបសង្កត់មកលើប្រជាពលរដ្ឋដែលទាមទារសិទ្ធិដីធ្លី និងសិទ្ធិលំនៅដ្ឋានរបស់ខ្លួន។
5. បញ្ឈប់ការបណ្តេញចេញដោយបង្ខំ ប៉ុន្តែត្រូវធ្វើការអភិវឌ្ឍន៍នៅនឹងកន្លែង។
6. ដោះលែងជាបន្ទាន់ប្រជាពលរដ្ឋដែលតវ៉ាទាមទារសិទ្ធិដីធ្លី និងសិទ្ធិលំនៅដ្ឋានចេញពីពន្ធនាគារ។
7. បញ្ឈប់ការរារាំងសកម្មភាពអហឹង្សារបស់ប្រជាពលរដ្ឋរងគ្រោះ ឧទាហរណ៍ ការដាក់ញត្តិ សំណូមពរផ្សេងៗទៀត។

**សំរាប់ម្ចាស់ជំនួយ**

1. ជួយបន្តការគាំទ្ររាល់គម្រោង និងសកម្មភាពដោះស្រាយទៅលើបញ្ហាទំនាស់ដីធ្លី និងលំនៅដ្ឋាន ប្រកបដោយប្រសិទ្ធភាព។
2. បន្តសហការជាមួយរាជរដ្ឋាភិបាលក្នុងការចុះបញ្ជីដីធ្លីជាប្រព័ន្ធ និងជម្រុញឲ្យរាជរដ្ឋាភិបាលបន្តដោះស្រាយសំណូមពរ និងអនុសាសន៍ផ្សេងៗរបស់ប្រជាពលរដ្ឋរងគ្រោះ។

## ៨.បញ្ហាការចុះបញ្ជីដីធ្លី និងបញ្ហាទំនាស់ដី និងការអនុវត្តបទបញ្ជាលេខ០០១

ទោះបី គោលនយោបាយចាស់សកម្មភាពថ្មីរបស់រាជរដ្ឋាភិបាលក្នុងការកែទម្រង់វិស័យដីធ្លីនាពេលថ្មីៗនេះ និងការចេញបទបញ្ជាលេខ០០១ ជាចំណាត់ការទាន់ពេលវេលា និងគួរឲ្យសរសើរយ៉ាងណាក៏ដោយ ក៏មកដល់ពេលនេះ យើងសង្កេតឃើញថានៅមានបញ្ហាប្រឈមខ្លះៗក្នុងការអនុវត្តជាក់ស្តែង និងធ្វើឲ្យចំណាត់ការនេះមានប្រសិទ្ធភាព។ ជាក់ស្តែងការចុះបញ្ជីដីធ្លី និងទំនាស់ដីធ្លីនៅតែកើតមានឡើង និងមិនទាន់អាចជម្រុញឲ្យមានការដោះស្រាយបញ្ហានេះបានពេញលេញឡើយ។ បញ្ហាប្រឈមអាចមានដូចជា៖ បទបញ្ជា០០១ នេះមិនមានវិសាលភាពគ្រប់ដណ្តប់លើតំបន់សម្បទានដីសង្គមកិច្ច ដែលនាំឲ្យការដោះស្រាយការទាមទាររបស់ប្រជាពលរដ្ឋនៅតំបន់មួយចំនួននោះមិនអាចធ្វើបានឡើយ។ ការឈូសបំផ្លាញដំណាំ និងការរំលោភដីធ្លីពីសំណាក់ក្រុមហ៊ុននៅតែមាន បើទោះជាមានបទបញ្ជា០០១ របស់រាជរដ្ឋាភិបាលក៏ដោយ។ ម្យ៉ាងទៀត ការងាររបស់ក្រុមយុវជនស្ម័គចិត្តមួយចំនួនតូចដែលបានចុះវាស់វែងដីធ្លីជូនប្រជាពលរដ្ឋ ដែលកំពុងមានបញ្ហាដីធ្លី នៅមិនទាន់អនុវត្តន៍ឲ្យបានពេញលេញ និងតាមស្ថានភាពជាក់ស្តែង ដោយអនុលោមទៅតាមបទបញ្ជា០០១ របស់រាជរដ្ឋាភិបាលនៅឡើយ។

➢ **សមិទ្ធិផលរបស់រាជរដ្ឋាភិបាល**

ជាមួយនឹងបញ្ហាប្រឈមទាំងនេះ យើងក៏សង្កេតឃើញមានការរីកចំរើនមួយចំនួនផងដែរ ចំពោះបញ្ហាខាងលើ។ អាជ្ញាធរមានសមត្ថកិច្ចបានដោះស្រាយ និងដកដីផ្នែកខ្លះពីក្រុមហ៊ុនមួយចំនួនឱ្យប្រជាពលរដ្ឋវិញ។ ចំណែកឯប្រជាពលរដ្ឋមួយចំនួនទៀតដែលមិននៅក្នុងតំបន់កំណត់ដោយបទបញ្ជាលេខ០០១ ក៏បានទទួលប័ណ្ណកម្មសិទ្ធិដីធ្លី ដែលនេះ គឺជាអ្វីដែលប្រជាពលរដ្ឋពេញចិត្ត និងជម្រុញឲ្យមានការដោះស្រាយឲ្យកាន់តែមានប្រសិទ្ធភាពបន្ថែម។ នៅតំបន់ខ្លះ ក្រោយពីដោះស្រាយដីធ្លីរួច អាជ្ញាធរក៏បានរៀបចំឲ្យមានប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធសម្រាប់ប្រជាពលរដ្ឋរស់នៅតំបន់នោះដែរ។

➢ **អនុសាសន៍**

**សំរាប់រាជរដ្ឋាភិបាល**

1. ដោះស្រាយនិងវាស់វែងដីធ្លីក្នុងតំបន់ដែលមានវិវាទ និងបញ្ហាជាក់ស្តែងឲ្យបានឆាប់រហ័ស។
2. បង្កើតយន្តការតាមដាន និងវាយតំលៃប្រសិទ្ធភាពការងាររបស់ក្រុមយុវជនស្ម័គ្រចិត្ត និង អាជ្ញាធរ ក្នុងការចូលរួមវាស់វែងដោះស្រាយវិវាទដីធ្លី។
3. រៀបចំចំណាត់ថ្នាក់សម្រាប់ប្រើប្រាស់និងផ្តល់សម្បទានដីសង្គមកិច្ច ដល់ប្រជាពលរដ្ឋក្រីក្រ ដែលគ្មានដីពិតប្រាកដ។
4. ពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋរងផលប៉ះពាល់ឲ្យបានទូលំទូលាយ និងដោះស្រាយបញ្ហាដោយសន្តិវិធី ព្រមទាំងទូទាត់សំណងក្នុងតម្លៃអាចទទួលបានពីភាគីរងផលប៉ះពាល់។

**សំរាប់ម្ចាស់ជំនួយ**

1. តាមដានការអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល ជាពិសេសក្នុងការអនុវត្តបទបញ្ជាលេខ០០១។
2. បន្តការគាំទ្រដល់សកម្មភាពរបស់អង្គការសង្គមស៊ីវិល និងសហគមន៍ ក្នុងការធ្វើការងាររបស់ខ្លួនលើវិស័យដីធ្លី ដើម្បីធានាបាននូវសុវត្ថិភាពដីធ្លី និងចូលរួមកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។

**សម្រាប់ព័តមានបន្ថែម សូមទាក់ទង៖**


- អ្នកស្រី **ខា ស្រស់** តំណាងសហគមន៍លើវិស័យរ៉ែ លេខទូរស័ព្ទ 097 503 0567
- លោក **រស់ ហាន** តំណាងសហគមន៍លើវិស័យរ៉ែ លេខទូរស័ព្ទ 012 1827 245
- លោក **ជា ជួង** តំណាងសហគមន៍ជនជាតិដើមភាគតិចនិងព្រៃឈើ លេខទូរស័ព្ទ 097 9690715
- លោក **ពេជ្រ នឹមឃួន** តំណាងសហគមន៍លើវិស័យដីធ្លី និងលំនៅដ្ឋាន លេខទូរស័ព្ទ 017 872 195
- លោក **ធន សារាយ** ប្រធាន សមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា (ADHOC) លេខទូរស័ព្ទ 016 440 044
- លោក **សួន ប៊ុនស័ក្តិ** លេខាធិការប្រតិបត្តិ គណៈកម្មាធិការប្រព្រឹត្តិកម្មនៃអង្គការសមាគម

ការពារសិទ្ធិមនុស្សកម្ពុជា (CHRAC) លេខទូរស័ព្ទ 092 344 357

- លោក **ឡាំ សុជាតិ** នាយករង វិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ (API) លេខទូរស័ព្ទ 077 555 679
- លោក **ឈិត សំអាត** នាយកប្រតិបត្តិ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា (The NGO Forum on Cambodia) លេខទូរស័ព្ទ 012 928 585
- លោក **ម៉ម សម្បត្តិ** នាយកប្រតិបត្តិ អង្គការអភិវឌ្ឍន៍និងភាពជាដៃគូក្នុងសកម្មភាព (DPA) លេខទូរស័ព្ទ 012 779 734
- លោក **យ៉េង វីរៈ** នាយកប្រតិបត្តិ មជ្ឈមណ្ឌលអប់រំច្បាប់សំរាប់សហគមន៍ (CLEC) លេខទូរស័ព្ទ  012 801 235
- លោក **គល់ បញ្ញា** នាយកប្រតិបត្តិគណៈកម្មាធិការដើម្បីរៀបចំការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (COMFREL) លេខទូរស័ព្ទ012 942 017
- លោក **ឆាយ សារ៉ាត** នាយកប្រតិបត្តិ សម្ព័ន្ធភាពកម្ពុជាដើម្បីតម្លាភាពចំណូលធនធា (CRRT) លេខទូរស័ព្ទ 012 589 958
- លោក **ប៉ែន សុមុន្នី** នាយកប្រតិបត្តិ អង្គការស្ម័គ្រចិត្តដើម្បីសង្គម (CVS) លេខទូរស័ព្ទ 012 708 093
- លោកស្រី **រស់ សុភាព** នាយិការប្រតិបត្តិ អង្គការយេនឌ័រនិងការអភិវឌ្ឍន៍ដើម្បីកម្ពុជា (GAD/C) លេខទូរស័ព្ទ 012 627 857
- លោក **សៀ ភារម្យ** នាយកលេខាធិការដ្ឋាន ក្រុមការងារពិសេសសិទ្ធិលំនៅឋាន (HRTF) លេខទូរស័ព្ទ 012 852 325
- លោក **សៅ វ៉ាន់សី** នាយកប្រតិបត្តិ អង្គការគាំទ្រសហគមន៍ជនជាតិដើមភាគតិច (ICSO) លេខទូរស័ព្ទ 012 813 744
- លោក **ឈួន បូរិទ្ធ** នាយកប្រតិបត្តិ អង្គការយុវជនខ្មែរនិងការអភិវឌ្ឍន៍សង្គម (KYSD) លេខទូរស័ព្ទ 012 798 488
- លោក **សាម អ៊ិន** នាយកប្រតិបត្តិ អង្គការជីវិតថ្លៃថ្នូរ (LWD) លេខទូរស័ព្ទ 012 55 18 86
- លោកស្រី **ជេត ចរិយា** នាយិកាប្រតិបត្តិ អង្គការស្តារកម្ពុជា (Star Kampuchea) លេខទូរស័ព្ទ 012 802 460
- លោក **ជាង សុខា** នាយកប្រតិបត្តិ អង្គការកម្មវិធីអភិវឌ្ឍន៍ធនធានយុវជន(YRDP) លេខទូរស័ព្ទ 012 360 464
- លោក **ស៊ឹម តារា** មន្ត្រីគ្រប់គ្រងគម្រោងជាន់ខ្ពស់ អង្គការទស្សនៈពិភពលោក (WVC) លេខទូរស័ព្ទ 012 771 051
- លោក **គឹម សុវណ្ណ** នាយកប្រតិបត្តិ អង្គការវីជីឡែន (Vigilance) លេខទូរស័ព្ទ 012 957 282